Vol. 2, No. 7 / ខែមីនា 2026

EQUITY ENGAGEMENT & PARTNERSHIPS
LONG BEACH UNIFIED SCHOOL DISTRICT

ព្រឹត្តិបត្រព័ត៌មាន

@lbusdengage lbschools.net/engage

LONG BEACH UNIFIED • SCHOOL • DISTRICT
Excellence and Equity

សូមអំពាវនាវដល់សហគមន៍របស់មន្ទីរអប់រំ LBUSD៖ សិស្សានុសិស្ស បុគ្គលិក ឪពុកម្តាយ និង អាណាព្យាបាល

យើងខ្ញុំត្រូវការមតិយោបល់របស់អ្នក ដើម្បីបន្សុំគោលដៅ និងសកម្មភាពរបស់ផែនការ LCAP បច្ចុប្បន្ន ឱ្យស្របគ្នាជាមួយកម្មវិធី និង សេវាកម្មដែលសំខាន់ៗ ក្នុងការគាំទ្រដល់សិស្សានុសិស្សឱ្យទទួលជោគជ័យ ជាមួយធនធានសម្រាប់ឆ្នាំ 2026-27។

ស្កែនកូដ QR នេះ៖
LBSchools.net/LCAP

LONG BEACH UNIFIED • SCHOOL • DISTRICT
Excellence and Equity

ថតស្កែន ឬ ចុចលើកូដ QR ដើម្បីចុះឈ្មោះ

ព្រឹត្តិការណ៍ដ៏សំខាន់មួយ

ThoughtExchange

នៅក្នុងការចុះផ្សាយនេះ

- C.A.F.E. – ចំណុចសំខាន់ៗពីបទបង្ហាញ ផែនការគ្រប់គ្រង និងគណនេយ្យភាព ប្រចាំមូលដ្ឋាន (LCAP) របស់មន្ទីរអប់រំ LBUSD (ទំព័រ 3)
- ព័ត៌មានថ្មីៗអំពីជម្រើស អនុវិទ្យាល័យ និង វិទ្យាល័យ (ទំព័រ 4)
- វីដេអូ អំពីបច្ចុប្បន្នភាពថវិកា (ទំព័រ 4)
- កាលវិភាគកិច្ចប្រជុំក្រុមមាតាបិតា (ទំព័រ 2 និង 5)
- ការជួយធ្វើឯកសារពន្ធចំណូល ដោយឥតគិតថ្លៃ នៅមហាវិទ្យាល័យ CSULB (ទំព័រ 4)



រួមជាមួយគ្នា គឺយើងកំពុងកសាងអនាគតកាន់តែប្រសើរមួយ ទាំងនៅក្នុង និងជាមួយសហគមន៍របស់យើង!

ខែមីនា នៅតែបន្តនាំមកនូវឱកាសជាច្រើន សម្រាប់គ្រួសារ បុគ្គលិក និងសមាជិកសហគមន៍ ធ្វើការរក្សាទំនាក់ទំនង និងចូលរួមជាមួយគ្នា។ ខណៈពេលដែលយើងកំពុងធ្វើការទៅមុខបន្ថែមទៀត នៅក្នុងឆមាសទីពីរ នាពេលពាក់កណ្តាលឆ្នាំសិក្សានេះ គឺយើងនៅតែបន្តប្តេជ្ញាចិត្តក្នុងការបង្កើតមធ្យោបាយដ៏មានអត្ថន័យជាច្រើន ដើម្បីឱ្យសហគមន៍របស់យើងបញ្ចេញមតិយោបល់ និងបន្តទទួលព័ត៌មានបានអំពីកិច្ចការគាំទ្រដល់សិស្សរបស់យើង។

នៅខែនេះ យើងសូមលើកទឹកចិត្តដល់អ្នក ឱ្យបន្តធ្វើការចែករំលែកសម្លេងរបស់អ្នកតាមរយៈ ThoughtExchange ដែលជាដំណើរការមួយចំណែកក្នុងការផ្តល់មតិកែលម្អលើ ផែនការគ្រប់គ្រង និងគណនេយ្យភាពប្រចាំមូលដ្ឋាន (LCAP)។ មតិកែលម្អរបស់អ្នក គឺជួយលើកបង្ហាញអំពីកម្មវិធី និងសេវាកម្មផ្សេងៗ ដែលសហគមន៍របស់យើងយល់ថា មានសារៈសំខាន់ក្នុងការគាំទ្រភាពជោគជ័យនៃសិស្សរបស់យើង តាមរយៈការប្រើធនធានដែលកំពុងតែមានស្រាប់។

យើងខ្ញុំសូមអញ្ជើញអ្នកចូលរួមជាមួយពួកយើង នៅក្នុងសិក្ខាសាលា ស្តីអំពីសិស្សរៀនភាសាអង់គ្លេស ដែលនឹងប្រព្រឹត្តទៅនៅ ថ្ងៃទី28 ខែមីនា នៅវិទ្យាល័យ Browning។ ព្រឹត្តិការណ៍នេះ គឺនឹងនាំគ្រួសារ បុគ្គលិក និងសមាជិកសហគមន៍ មកជុំគ្នារយៈពេលមួយថ្ងៃ ដើម្បីសិក្សាជាមួយគ្នា ទំនាក់ទំនងគ្នា និងធ្វើការអបអរចំពោះសហគមន៍របស់យើង ដែលប្រើពហុភាសា។

សូមអរគុណចំពោះការចូលរួមចំណែកដ៏សំខាន់នៅក្នុងកិច្ចការនេះ និងជួយធ្វើយ៉ាងណា ដើម្បីធានាថា សាលារៀនរបស់យើង គឺពិតជានៅតែបន្តធ្វើការឆ្លុះបញ្ចាំងទៅលើសម្លេង និងអាទិភាពរបស់សហគមន៍មែន ដែលយើងខ្ញុំមានតួនាទីធ្វើការបម្រើ។

Dr. Lucy Salazar



ក្រុមសម្រាប់ការចូលរួមរបស់មាតាបិតា



ក្រុមមាតាបិតានានា

បន្ថែមពីលើកម្មវិធី CAFE គឺក្រុមគ្រួសារអាចចូលរួមក្នុងក្រុមមាតាបិតាផ្សេងៗទៀតបាននៅមន្ទីរអប់រំ ដែលកសាងជំនាញ និងបទពិសោធន៍ដែលពួកគេនាំមក ខណៈពេលដែលផ្តល់ឱកាសដ៏មានអត្ថន័យសម្រាប់ភាពជាអ្នកដឹកនាំ ភាពរីកចម្រើន និងការសិក្សា។ ក្រុមទាំងនេះ នាំមាតាបិតានានាមកជួបជុំគ្នា ដើម្បីស្វែងយល់អំពីគំនិតផ្តួចផ្តើមរបស់មន្ទីរអប់រំ ចែករំលែកមតិយោបល់ និងសហការគ្នារិះរកមធ្យោបាយ ដើម្បីជួយជ្រោមជ្រែងដល់សិស្សទាំងអស់បាន។ តាមរយៈការចូលរួម មាតាបិតាមិនត្រឹមតែពង្រឹងជំនាញភាពជាអ្នកដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ គឺថែមទាំងជួយបង្កើតអនាគតនៃសាលារៀន និងសហគមន៍របស់យើងផងដែរ។



DISTRICT COMMUNITY ADVISORY COMMITTEE

LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសហគមន៍ប្រចាំមន្ទីរអប់រំ (DCAC) គឺមានសមាសភាគជាតំណាងមាតាបិតា មកពីសាលារបស់មន្ទីរអប់រំ LBUSD ទាំងឡាយ ដែលឧបត្ថម្ភដោយមូលនិធិសហព័ន្ធ Title 1។ មាតាបិតា ត្រូវបានផ្តល់ឱកាសឱ្យចូលរួមពាក់ព័ន្ធ និងទទួលដំណឹងអំពីការសិក្សារបស់កូនពួកគាត់។ មាតាបិតា ត្រូវបានលើកទឹកចិត្តឱ្យចែករំលែកព័ត៌មានអំពីកិច្ចប្រជុំ ជាមួយមាតាបិតាផ្សេងៗទៀត នៅសាលារបស់ពួកគេ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃព្រហស្បតិ៍ ទី26 ខែមីនា នៅវិទ្យាល័យ Browning – ម៉ោង 5:30 ល្ងាច**



DISTRICT ENGLISH LEARNER ADVISORY COMMITTEE

LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសិស្សរៀនភាសាអង់គ្លេសប្រចាំមន្ទីរអប់រំ (DELAC) គឺជាវិធីសម្រាប់មាតាបិតា អាចចូលរួមចំណែកក្នុងការអប់រំរបស់កូនពួកគេ នៅកម្រិតមន្ទីរអប់រំបាន។ ជារៀងរាល់ខែ មានតំណាងរបស់ DELAC មាតាបិតា ថ្នាក់ដឹកនាំមន្ទីរអប់រំ និងសមាជិកសហគមន៍ ចូលរួមក្នុងការប្រជុំទាំងនេះ ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃអង្គារ ទី3 ខែមីនា នៅវិទ្យាល័យ Browning – ម៉ោង 9:30 ព្រឹក**



SANKOFA PARENT VILLAGE

LONG BEACH UNIFIED SCHOOL DISTRICT

ភូមិមាតាបិតាសាំងកូហ្វា (SPV) ជាសហគមន៍មើលថែ និងជួយផ្គត់ផ្គង់សម្រាប់មាតាបិតា និងអ្នកមើលថែរបស់កុមារអាមេរិកខ្មៅ។ មន្ទីរអប់រំ LBUSD ប្តេជ្ញាផ្តោតចិត្តទុកដាក់លើតម្រូវការពិសេសរបស់សមាជិកសហគមន៍របស់យើង និងចូលរួមតាមរបៀបដែលលើកកំពស់ដល់អត្តសញ្ញាណវប្បធម៌របស់ពួកគេ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃច័ន្ទ ទី16 ខែមីនា នៅមជ្ឈមណ្ឌលធនធានគ្រូបង្រៀន – TRC ម៉ោង 5:30 ល្ងាច**



EDUCATIONAL OPPORTUNITIES for NATIVE AMERICANS and NATIVE ALASKANS

LONG BEACH UNIFIED SCHOOL DISTRICT

កម្មវិធីរបស់យើង ត្រូវបានរបង្កើតឡើង ដើម្បីធានាថា សិស្សជនជាតិដើមអាមេរិក (AI)/ និងជនជាតិដើមអាឡាស្កា (AN) នៅក្នុងមន្ទីរអប់រំឡុងប៊ីច មានឱកាសស្មើភាពគ្នា ក្នុងការទទួលបានការអប់រំ។ មាតាបិតា អាណាព្យាបាល បុគ្គលិកមន្ទីរ និងដៃគូនៅតាមសហគមន៍ ចូលរួមក្នុងការធ្វើផែនការកម្មវិធីសិក្សា និងព្រឹត្តិការណ៍ផ្សេងៗ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃអង្គារ ទី14 ខែមេសា នៅវិទ្យាល័យ Browning បន្ទប់ប្រជុំធំ – ម៉ោង 5:30 ល្ងាច**



សិក្ខាលាសម្រាប់មាតាបិតា
ដើម្បីរៀនសូត្រ រីកចំរើន និងពង្រឹងសមត្ថភាព រួមជាមួយគ្នា៖ នៅក្នុង និង ជាមួយ សហគមន៍

C.A.F.E.
ការចូលរួមសំរាប់សហគមន៍ និង គ្រួសារ



កម្មវិធី C.A.F.E. នៅខែកុម្ភៈរបស់យើង មានការធ្វើបទបង្ហាញដោយ Dr. Lucy Salazar និង Carmen Hernnadez នៃការិយាល័យសមធម៌ ការចូលរួម និងភាពជាដៃគូ (EEP)។ បទបង្ហាញរបស់ពួកគេទាំងពីរ បានធ្វើការផ្តោតលើការគ្រប់គ្រង និង គណនេយ្យភាពប្រចាំនូលដ្ឋាន (LCAP) និង ប្រព័ន្ធ ThoughtExchange របស់មន្ទីរអប់រំ LBUSD ដែលស្នើសុំមតិកែលម្អពីសហគមន៍។











សូមចូលរួមជាមួយយើងខ្ញុំ ក្នុងកម្មវិធី C.A.F.E. លើកក្រោយរបស់យើង
នៅថ្ងៃសុក្រ ទី20 ខែមីនា ឆ្នាំ2026 វេលាម៉ោង 9:30 ព្រឹក
នៅវិទ្យាល័យ Browning
2180 Obispo Ave., Long Beach, CA 90804

PARENT UNIVERSITY
LONG BEACH UNIFIED SCHOOL DISTRICT



សិក្ខាសាលាជាច្រើនវគ្គ ដែលត្រូវបានបង្កើតឡើងដើម្បីគាំទ្រ និងពង្រឹងសមត្ថភាពដល់គ្រួសារនានាឱ្យក្លាយជាដៃគូពេញលេញក្នុងការអប់រំកូនរបស់ពួកគេ។
ឪពុកម្តាយ និងអ្នកមើលថែ នៅមន្ទីរអប់រំ LBUSD ត្រូវបានស្វាគមន៍ឱ្យចូលរួម។ មានសេវាដឹកជញ្ជូន សេវាមើលថែក្មេង ជំនួយផ្នែកធ្វើលំហាត់សិក្សា និងសេវាបកប្រែភាសា។





សូមចូលរួមជាមួយយើងខ្ញុំ នៅថ្ងៃព្រហស្បតិ៍ ទី12 ខែមីនា ឆ្នាំ2026
ក្នុងសិក្ខាសាលាមួយ ដែលស្តីអំពី ការទប់ស្កាត់ប្រើគ្រឿងញៀន
នៅវិទ្យាល័យ Browning ម៉ោង 5:30 ល្ងាច

សិក្ខាសាលាស្តីពីសិស្សរៀនភាសាអង់គ្លេស
សូមចូលរួមជាមួយយើងខ្ញុំ ដើម្បីប្រារព្ធអបអរដល់សហគមន៍ដែលប្រើពហុភាសារបស់យើង!



សូមចុចលើខិត្តប័ណ្ណនេះ សម្រាប់ព័ត៌មានបន្ថែម

សារជូនដំណឹង និង ធនធានព័ត៌មាន របស់មន្ទីរអប់រំ LBUSD



សូមចុចលើខិតប័ណ្ណនេះ សម្រាប់ព័ត៌មានបន្ថែម



ធនធានព័ត៌មានផ្សេងៗ សំរាប់ក្រុមគ្រួសារ
មន្ទីរអប់រំ LBUSD បានប្រមូលព័ត៌មានទុកជាបញ្ជីធនធាន សម្រាប់ក្រុមគ្រួសារចូលប្រើប្រាស់បាន។ រាប់តាំងពីការភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍ រហូតដល់ការសិក្សានៅមហាវិទ្យាល័យ និងការចាប់យកមុខអាជីព។ សូមចុច **<u>នៅទីនេះ។</u>**



សូមចុចលើខិត្តប័ណ្ណនេះ ដើម្បីទទួលព័ត៌មានបន្ថែមអំពីធនធាន

សហគមន៍របស់មន្ទីរអប់រំ LBUSD យើងខ្ញុំត្រូវការគំនិតរបស់អ្នក!

សម្រង់មតិតាម ‹‹ThoughtExchange›› លើផែនការគ្រប់គ្រង និង គណនេយ្យភាព ប្រចាំមូលដ្ឋាន (LCAP) ត្រូវបានបង្កើតឡើង ដើម្បីប្រមូលមតិ ពីសហគមន៍អំពីផែនការ LCAP។ សមាជិកសហគមន៍ អាចចូលរួមដោយប្រើប្រាស់តំណភ្ជាប់ខាងក្រោម ឬ ស្កេនលេខកូដ QR។ ការធ្វើសម្រង់មតិនេះ នឹងត្រូវបញ្ចប់នៅថ្ងៃទី31 ខែមីនា ខាងមុខនេះ។



ការជួយធ្វើឯកសារពន្ធចំណូល ដោយឥតគិតថ្លៃ



<u>សូមចុចលើខិត្តប័ណ្ណនេះ សម្រាប់ព័ត៌មានបន្ថែម</u>

ការធ្វើបច្ចុប្បន្នភាពថវិកា នៅខែមីនា ឆ្នាំ2026

មន្ទីរអប់រំ ឡុងប៊ិច បន្តធ្វើផែនការយ៉ាងប្រុងប្រយ័ត្នពេញមួយឆ្នាំ ដើម្បីដោះស្រាយឱនភាពថវិការជាប្រព័ន្ធ ដែលបណ្តាលមកពីធ្លាក់ចុះការចុះឈ្មោះចូលរៀន តម្លៃចំណាយឡើងថ្លៃ និងប្រាក់ចំណូលដែលមានកំណត់ជាហូរហែរ។ ខណៈពេលដែលយើងរៀបចំសម្រាប់ឆ្នាំសិក្សា 2026-27 គឺយើងកំពុងចាត់វិធានការ ដើម្បីសម្រួលការងារបុគ្គលិក ឱ្យស្របនឹងធនធាន ខណៈពេលដែលបន្តផ្តល់អាទិភាពដល់សេវាកម្ម និងការគាំទ្រដោយផ្ទាល់សម្រាប់សិស្ស។ សម្រាប់ខ្លឹមសារបន្ថែម អំពីស្ថានភាព ហិរញ្ញវត្ថុរបស់មន្ទីរអប់រំ និងផលប៉ះពាល់លើបុគ្គលិក ពីការសម្រេចចិត្តទាំងនេះ សូមមើល**សេចក្តីថ្លែងការណ៍របស់អគ្គនាយក**ទៅកាន់ក្រុមប្រឹក្សាភិបាលអប់រំ កាលពីពេលថ្មីៗនេះ។

ការប្តេជ្ញាចិត្តរបស់យើង
យើងទទួលស្គាល់ថា ការផ្លាស់ប្តូរបុគ្គលិក គឺប៉ះពាល់ដល់មិត្តរួមការងារ និងសហគមន៍សាលារបស់យើង។ ការសម្រេចចិត្តទាំងនេះ ត្រូវបានធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន លើស្ថានភាពហិរញ្ញវត្ថុ និងតម្រូវការសិស្សរបស់មន្ទីរអប់រំ។

មន្ទីរអប់រំ ឡុងប៊ិច នៅតែប្តេជ្ញាការពារបទពិសោធន៍ក្នុងថ្នាក់រៀន ការគាំទ្រសិស្ស និងបរិយាកាសសិក្សាដែលមានសុវត្ថិភាព ខណៈពេលដែលទ្រទ្រង់ស្ថិរភាពហិរញ្ញវត្ថុដែលត្រូវការ ដើម្បីរក្សាសេវាកម្មទាំងនេះនៅក្នុងឆ្នាំខាងមុខ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះស្មារតីការងាររបស់បុគ្គលិកយើង និងកិច្ចសហការដ៏តូចតាចឈប់ឈរ របស់ក្រុមគ្រួសារ និងសហគមន៍របស់យើង។

<u>lbschools.net/budget.</u>



ព្រឹត្តិការណ៍ព័ត៌មាន អំពីការជ្រើសរើសសាលារៀន សម្រាប់អនុវិទ្យាល័យ និង សាលាថ្នាក់មត្តេយ្យ ដល់ទី8



សូមចុចលើខិត្តប័ណ្ណនេះ សម្រាប់ព័ត៌មានបន្ថែម

ព្រឹត្តិការណ៍ និងឱកាសដើម្បីចូលរួមក្នុងពេលឆាប់ៗខាងមុខនេះ

សូមពិនិត្យមើលផ្នែកនេះជារៀងរាល់ខែ សម្រាប់សិក្ខាសាលា កិច្ចប្រជុំក្រុមឪពុកម្តាយ និងព្រឹត្តិការណ៍នានារបស់មន្ទីរអប់រំ ដែលធ្វើនាពេលឆាប់ៗខាងមុខនេះ។ សូមកុំខកខានឱកាសដើម្បីភ្ជាប់ទំនាក់ទំនង រៀនសូត្រ និងចូលរួមជាមួយសហគមន៍សាលារៀនរបស់យើង។

ខែមីនា

អាទិត្យ	ច័ន្ទ	អង្គារ	ពុធ	ព្រហស្បតិ៍	សុក្រ	សៅរ៍
			ការប្រជុំក្រុមប្រឹក្សាភិបាល ម៉ោង 5 ល្ងាច	ប្រជុំ Parent University តាមអនឡាញ ម៉ោង 6:00 ល្ងាច		ពិធីអបអរ និងបង្ហាញអំពីមត្តេយ្យសិក្សា ម៉ោង 9 ព្រឹក
8 ថ្ងៃប្តូរម៉ោងសម្រាប់រដូវថ្មី	9	10 ការជួបពិភាក្សាគោលដៅ និងវិធានការទ្រទ្រង់របស់ក្រុមប្រឹក្សាភិបាល 6:00 ល្ងាច	11 ការប្រជុំ CAC នៅវិទ្យាល័យ Browning ម៉ោង 6:00 ល្ងាច	12 ការប្រជុំ Parent University នៅវិទ្យាល័យ Browning ម៉ោង 5:30 ល្ងាច	13	14
15	16 ការប្រជុំ Sankofa សម្រាប់មាតាបិតាអាមេរិកខ្មៅ ម៉ោង 5:30 ល្ងាច	17 ការប្រជុំ EONA នៅវិទ្យាល័យ Browning ម៉ោង 5:30 ល្ងាច CANCELLED	18 ការប្រជុំក្រុមប្រឹក្សាភិបាល ម៉ោង 5 ល្ងាច	19	20 កម្មវិធី C.A.F.E. នៅសាលា Educare ម៉ោង 9:30 ព្រឹក	21
22	23	24	25	26 ការប្រជុំ DCAC នៅវិទ្យាល័យ Browning ម៉ោង 5:30–6:30 ល្ងាច	27	28 សិក្ខាសាលាស្តីពីសិស្សរៀនភាសាអង់គ្លេស ម៉ោង 9 ព្រឹក
29	30	31 ការប្រជុំ DELAC នៅវិទ្យាល័យ Browning ម៉ោង 9:30 ព្រឹក				

Parent University



C.A.F.E.



DCAC



EONA



DELAC

